**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

## សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល

## ស្តីពី ករណីវិជ្ជមានកូវីដ១៩ លើស្ត្រីជនជាតិអង់គ្លេសម្នាក់អាយុ៦៥ឆ្នាំ ជាអ្នកដំណើរតាមនាវាទេសចរណ៍ (Viking Cruise Journey) នៅខេត្តកំពង់ចាម នៃព្រះរាជាណាចក្រកម្ពុជា

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបថា នៅរសៀលម៉ោង១៦:៣០នាទីនៃថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ លទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា បានបញ្ជាក់ថា **ស្ត្រីជនជាតិអង់គ្លេសម្នាក់ អាយុ ៦៥ឆ្នាំ មានវិជ្ជមានវីរុសកូវីដ១៩។** ស្ត្រីរូបនេះ ជាអ្នកដំណើរតាមនាវាឈ្មោះ Viking Cruise Journey ចេញពីកំពង់ផែ My Tho នៃទីក្រុងហូជីមិញ សំដៅមកទីក្រុងភ្នំពេញ តាមរយៈច្រកទ្វារ ក្អមសំណរ និងហួសទៅចូលចតប្រហែលជាម៉ោង១៦:៣០នាទីរសៀល នៅចំណតនាវានៃទីរួមខេត្តកំពង់ចាម។ បច្ចុប្បន្ន ក្រសួងសុខាភិបាលកំពុងចាត់ចែងឲ្យយកស្ត្រីជនជាតិអង់គ្លេសរូបនោះ មកដាក់នៅបន្ទប់ដាច់ដោយឡែកក្នុងមន្ទីរពេទ្យខេត្តកំពង់ចាម ដើម្បីព្យាបាល និងតាមដានសុខភាពគាត់។ ទន្ទឹមនឹងនោះ មានស្ត្រីជនជាតិអង់គ្លេសម្នាក់ទៀតដែលជិតដិតជាមួយស្ត្រីជនជាតិអង់គ្លេសមានវីរុសកូវីដ១៩រូបនេះ មានលទ្ធផលតេស្តអវិជ្ជមាន ដែលបុគ្គលរូបនេះ ត្រូវបានដាក់ឲ្យនៅក្នុងបន្ទប់ដាច់ដោយឡែកនៅលើនាវា ហើយអ្នកដំណើរផ្សេងទៀតសរុបចំនួន ៣០នាក់ និងបុគ្គលិកបម្រើការនាវាសរុបចំនួន ៣៤នាក់ (សរុបទាំងអស់ ៦៤នាក់) ត្រូវឲ្យនៅលើនាវាទាំងអស់ មិនឲ្យចុះចេញមកលើគោក ដោយរង់ចាំក្រុមការងារឆ្លើយតបបន្ទាន់នៃមន្ទីរសុខាភិបាលខេត្តកំពង់ចាម និងក្រសួងសុខាភិបាលយកសំណាកវត្ថុវិភាគមកធ្វើតេស្តនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា។

ស្ត្រីមានវីរុសកូវីដ១៩ ខាងលើ បានធ្វើដំណើរតាមយន្តហោះចេញពីទីក្រុងឡុងនៃប្រទេសអង់គ្លេស មកដល់ទីក្រុងហាណូយ ប្រទេសវៀតណាម នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ ដែលមានគ្នា៥នាក់ (ជាជនជាតិអង់គ្លេសទាំងអស់ធ្វើតេស្តអវិជ្ជមានចំនួន៤នាក់)។ បន្ទាប់មក ពួកគាត់បានបន្តដំណើរចាកចេញតាមនាវាខាងលើ ពីទីក្រុងហូជីមិញសំដៅមករាជធានីភ្នំពេញ នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ និងបានមកដល់រាជធានីភ្នំពេញនៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២០។ នៅថ្ងៃដដែលមុននឹងមកដល់រាជធានីភ្នំពេញ អ្នកទទួលខុសត្រូវអ្នកទេសចរនៃនាវានេះ បានទទួលដំណឹងថា យន្តហោះដែលស្ត្រីជនជាតិអង់គ្លេសបានជិះនៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ នោះ មានជនជាតិវៀតណាមម្នាក់ដែលអង្គុយជិតស្ត្រីជនជាតិអង់គ្លេសអាយុ ៦៥ឆ្នាំខាងលើនេះ ត្រូវបានរកឃើញវិជ្ជមានវីរុសកូវីដ១៩ នៅទីក្រុងហាណូយ។ ពេលមកដល់រាជធានីភ្នំពេញនៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២០ ជនជាតិអង់គ្លេសទាំង៥រូប ត្រូវបានបញ្ជូនទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ហើយបានយកសំណាកវត្ថុវិភាគចំនួន០៣នាក់ (ដោយ០២នាក់ បានប្រកែកមិនព្រមឲ្យយកជាចំណាក់ដោយសំអាងថាពួកគាត់មិនមានបញ្ហាសុខភាព ឬរោគសញ្ញាអ្វីទាំងអស់)។ ជាលទ្ធផល អ្នកទាំង៣នាក់នេះមានអវិជ្ជមានវីរុសកូវីដ១៩។ ដើម្បីឲ្យមានភាពច្បាស់លាស់ មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត បានផ្តល់ព័ត៌មានមកមន្ទីរសុខាភិបាលខេត្តកំពង់ចាម ដើម្បីត្រៀមរង់ចាំយកវត្ថុសំណាកទាំង២នាក់ទៀតដែលមិនបានធ្វើតេស្តនោះ ដោយមានការសម្របសម្រួលពីអ្នកគ្រប់គ្រងនាវា នៅពេលចូលចតនៅចំណតនៃខេត្តកំពង់ចាម ហើយត្រូវបានក្រុមគ្រូពេទ្យពិនិត្យ និងបញ្ជូនសំណាកវត្ថុវិភាគមកវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០។ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង១៦:៣០នាទីរសៀលនេះ ក៏ទទួលបានលទ្ធផលវិជ្ជមានលើស្ត្រីជនជាតិអង់គ្លេសម្នាក់អាយុ ៦៥ឆ្នាំ។ សូមបញ្ជាក់ជូនថា បុគ្គលដែលសង្ស័យទាំង៥រូប ខាងលើនេះ ត្រូវបានឲ្យនៅក្នុងបន្ទប់ដាច់ដោយឡែកលើនាវាភ្លាមៗ ដោយមិនឲ្យចាកចេញមកលើគោកនៅរាជធានីភ្នំពេញឡើយនៅពេលរង់ចាំលទ្ធផល។

ក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលខេត្តកំពង់ចាម រួមសហការជាមួយអាជ្ញាធរខេត្តកំពង់ចាម យកចិត្តទុកដាក់ក្នុងការស្រាវជ្រាវ និងយកវត្ថុសំណាកពីអ្នកដែលបានប៉ះពាល់ផ្ទាល់ ឬប្រយោលនៅលើនាវាទាំងអស់ មកវិភាគនៅមន្ទីរពិសោធន៍នៃវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់ នៅទូទាំងប្រទេស ព្រមទាំងស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព ក៏ដូចជាជួយសម្របសម្រួលដល់អ្នកដំណើរតាមនាវាខាងលើនេះទាំងអស់ ហើយក្រសួងនឹងបន្តកិច្ចសហការជាមួយអាជ្ញាធរ ស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិ ជាបន្តទៀត រហូតដល់ប្រតិបត្តិការសុខាភិបាល ត្រូវបានបញ្ចប់។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តនៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអង្គារ ២រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០